# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ៣ ខែ សីហា ឆ្នាំ២០២២

## ទស្សនកិច្ចទៅកាន់ប្រទេសកម្ពុជា

យប់នេះ ខ្ញុំនឹងធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមក្នុង កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស អាស៊ាន-អូស្ត្រាលី កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងវេទិកាតំបន់អាស៊ាន (ARF) នៅសប្តាហ៍នេះ ។

ខ្ញុំរង់ចាំជួបជាមួយថ្នាក់ដឹកនាំ និងរដ្ឋមន្ត្រីក្នុងតំបន់ ដើម្បីបន្តធ្វើឱ្យកាន់តែស៊ីជម្រៅ នូវការចូលរួមរបស់រដ្ឋាភិបាលអូស្ត្រាលី ជាមួយអាស៊ីអាគ្នេយ៍។

នៅក្នុងកិច្ចប្រជុំអាស៊ាន ខ្ញុំនឹងគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ចំពោះមជ្ឈិមភាពអាស៊ាន បន្តកិច្ចសហប្រតិបត្តិការតាមរយៈភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរបស់យើង ក្នុងវិស័យដែលជាប្រយោជន៍រួម រួមទាំងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការបង្កើតសន្តិសុខសុខាភិបាល និងការជំរុញទស្សនទានរបស់អាស៊ានទៅលើតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

នៅក្នុងកិច្ចប្រជុំ EAS និង ARF ខ្ញុំនឹងបង្ហាញអំពីចក្ខុវិស័យរបស់អូស្ត្រាលីសម្រាប់តំបន់ និងជំហររបស់យើងចំពោះវិបត្តិនៅប្រទេសមីយ៉ាន់ម៉ា និងការឈ្លានពានរបស់ប្រទេសរុស្ស៊ីនៅប្រទេសអ៊ុយក្រែន។

ដំណើរទស្សនកិច្ចរបស់ខ្ញុំមកកម្ពុជា គឺចំពេលខួបទី៧០ឆ្នាំនៃទំនាក់ទំនងការទូតរបស់យើង។ ខ្ញុំនឹងជួបជាមួយសមាជិករដ្ឋាភិបាលកម្ពុជា ដើម្បីពិភាក្សាអំពីការស្តារសេដ្ឋកិច្ចឡើងវិញ ទំនាក់ទំនងអប់រំ សន្តិសុខសុខាភិបាល និងសិទ្ធិមនុស្ស។

ខ្ញុំក៏នឹងទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាល (ACE) ដើម្បីបើកសាខាថ្មីរបស់សាលានេះ។ សាលា ACE បានផ្តល់ការបណ្តុះបណ្តាលភាសាអង់គ្លេស ដល់ប្រជាជនកម្ពុជា ជាង ៥០០ ០០០ នាក់ ចាប់តាំងពីសាលាត្រូវបានបង្កើតឡើង កាលពី៣០ ឆ្នាំមុន។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au